# របាយការណ៍សង្ខេប

## ស្តីពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបាត់ដំបង

## ដោយឯកឧត្តម សុខ លូ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង

ជាបឋម ខ្ញុំសូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាន នៅក្នុងសន្និសីទសារព័ត៌មាននាឱកាសនេះ។ ក្នុងនាមរដ្ឋបាលខេត្តបាត់ដំបង និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំពិតជាមានកិត្តិយស និងក្តីសោមនស្សរីករាយដោយបានចូលរួមក្នុងសន្និសីទសារព័ត៌មាននាថ្ងៃនេះ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំនូវសន្និសីទសារព័ត៌មាន ស្តីពី "**ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមករបស់រដ្ឋបាលខេត្តបាត់ដំបង**" សូមអរគុណចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់នៅទីនេះ ។

ខ្ញុំសូមយកឱកាសនេះសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនូវចក្ខុវិស័យ និងគោលនយោបាយដ៏ត្រឹមត្រូវ រក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ ជាពិសេសរក្សាបាននូវកំណើនសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អត្រាប្តូរប្រាក់មានស្ថិរភាព រួមចំណែកនូវការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេសបានជាបន្តបន្ទាប់ នឹងឈានទៅប្រែក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ នៅក្នុងបរិការណ៍ បដិវត្តន៍ឧស្សាហកម្ម ៤.0 ការរីកចម្រើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសាកលបាន នឹងកំពុងលេចរូបរាង និងមានការវិវឌ្ឍយ៉ាងឆាប់រហ័ស។ បច្ចេកវិទ្យាឌីជីថលបាន និងកំពុងដើរតួនាទីជាស្នូល និងចលករនៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គម ដែលមានភាពសម្បូរបែប ប្រសិទ្ធភាព និងផលិតភាពនៃប្រតិបត្តិការការងារ នៅជុំវិញការរស់នៅប្រចាំថ្ងៃរបស់យើង។ មិនត្រឹមតែប៉ុណ្ណោះ តាមរយៈការដាក់ចេញនូវគោលនយោបាយឈ្នះ-ឈ្នះរបស់សម្តេចតេជោ បានធ្វើឱ្យប្រទេសជាតិវិលមករកនូវសុខសន្តិភាពយ៉ាងពេញលេញបរិបូរណ៍ ធ្វើឱ្យប្រជាពលរដ្ឋទាំងអស់នៅទូទាំងប្រទេសទទួលបាននូវសិទ្ធិសេរីភាពក្នុងការដើរហើរ និងការប្រកបមុខរបរចិញ្ចឹមជីវិតដោយពុំមានការភ័យខ្លាច ដែលការណ៍នេះបានជួយជម្រុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស ក៏ដូចជានៅតាមមូលដ្ឋានរាជធានី ខេត្តទាំងអស់។ ក្នុងនោះ ខេត្តបាត់ដំបង ក៏បានទទួលនូវផ្លែផ្កាយ៉ាងច្រើនរហូតមកដល់បច្ចុប្បន្ន ដោយបានប្រែក្លាយទឹកដីខេត្តពីស្ថានភាពលំបាកគ្មានការអភិវឌ្ឍក្នុងអំឡុងទសវត្សទី៨០ និងជាតំបន់សមរភូមិ មកជាតំបន់ដែលមានការអភិវឌ្ឍជាជំហានៗលើគ្រប់វិស័យ និងពីតំបន់ដែលមានមីន ទៅជាតំបន់សេដ្ឋកិច្ច ដែលមានរោងចក្រសហគ្រាសធំៗចូលវិនិយោគ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូនដល់អង្គសន្និសីទ មេត្តាជ្រាបថា នៅក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ រដ្ឋបាលខេត្តបាត់ដំបង ដោយមានការចូលរួមសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទាំងខេត្ត ខេត្តបាត់ដំបង បានខិតខំអនុវត្ត និងបំពេញការងារលើគ្រប់វិស័យដើម្បីឆ្លើយតបនូវគោលដៅអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្ត ចូលរួមអនុវត្តនូវកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ នៃរដ្ឋសភា(ឆ្នាំ២០១៨-២០២៣) ដែលសម្រេចបានសមិទ្ធផលជាច្រើន រួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត។ ឈរលើមូលដ្ឋានដែលសម្រេចបាននេះ ខេត្តបាត់ដំបងនៅតែរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បានល្អប្រសើរតាមរយៈការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងដោយមានការយកចិត្តទុកដាក់ជាប់ជាប្រចាំរបស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តបាត់ដំបង**។

**ឯកឧត្តម លោកជំទាវ!**

**ភ្ញៀវកិត្តិយស បងប្អូនអ្នកសារព័ត៌មានជាទីគោរពស្រលាញ់រាប់អាន!**

ដើម្បីឱ្យមានការយល់ច្បាស់អំពីស្ថានភាពទូទៅជារួមរបស់ខេត្តបាត់ដំបង ខ្ញុំសូមជម្រាបជូនដល់អង្គសន្និសីទឱ្យបានជ្រាបថា ខេត្តបាត់ដំបង ស្ថិតនៅភូមិភាគពាយព្យនៃព្រះរាជាណាចក្រកម្ពុជា តាមបណ្តោយផ្លូវជាតិលេខ៥ និងមានចម្ងាយ ២៩១គ.ម ពីរាជធានីភ្នំពេញ។ ខេត្តមានព្រំប្រទល់ខាងលិចទល់នឹងខេត្តប៉ៃលិន និងព្រះរាជាណាចក្រថៃឡង់ដ៍ **(រួមមាន ខេត្តត្រាត ច័ន្ទបុរី និងស្រះកែវ ដែលមានប្រវែងសរុប ១៤៤,៨គ.ម និងមានច្រកទ្វារព្រំដែនចំនួន ៥ គឺ ច្រកទ្វារព្រំដែនអន្តរជាតិ ២ និងច្រកទ្វារតំបន់ ៣)** ខាងកើតទល់នឹងបឹងទន្លេសាប ខាងជើងទល់នឹងខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ខាងត្បូងទល់នឹងខេត្តពោធិ៍សាត់។ ខេត្តបាត់ដំបងមានសណ្ឋានដីចែកជាបីតំបន់សំខាន់គឺ ទី១៖ តំបន់ខ្ពង់រាប និងតំបន់ព្រៃភ្នំ ដែលជាតំបន់ចំការឈើហូបផ្លែ និងដំណាំឧស្សាហកម្ម, ទី២៖ តំបន់វាលរាប (តំបន់ស្រែ) និងទី៣៖ តំបន់ទំនាបជាប់បឹងទន្លេសាប។

ខេត្តមានផ្ទៃដីសរុប **១១.៦៣១,២១** គីឡូម៉ែត្រការ៉េ ចែកចេញជា ក្រុង**០១** និងស្រុកចំនួន **១៣** ដែលបែងចែកបន្តជា **១០៣**ឃុំ-សង្កាត់ និង **៨៣៩**ភូមិ។ ប្រជាពលរដ្ឋសរុប **១.៣៦៧.៤០២**នាក់ (ស្រី **៦៨៧.៥៧២**នាក់) ដែលមាន **២៩៤.២៩៤** គ្រួសារ។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំ ២,១៦%, អត្រាមេគ្រួសារជាស្ត្រីមាន **១៣,៦៥%** ប្រជាពលរដ្ឋមានមុខរបរចំបងផ្នែកកសិកម្ម ចំនួន **៦៨,៥%** ផ្នែកសេវាកម្ម ចំនួន **៣១%** និង ផ្នែកសិប្បកម្ម ចំនួន **0,៥%** ។ បច្ចុប្បន្ននេះ សេដ្ឋកិច្ចខេត្តបាត់ដំបង មានចំនួនស្មើនឹង **៨,៨%** នៃសេដ្ឋកិច្ចជាតិ។ ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន **១.៧៦០** ដុល្លាអាមេរិក បើធៀបនឹងឆ្នាំ២០១៨ មានការកើនឡើងចំនួន **២២៦** ដុល្លាក្នុងម្នាក់ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូនអំពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តបាត់ដំបងមានដូចខាងក្រោម៖

**១-<u>ការងារគ្រប់គ្រងរដ្ឋបាល</u> ៖**

បន្ទាប់ពីទទួលបានការធ្វើសមាហរណកម្មការិយាល័យជំនាញនានាជុំវិញក្រុង ស្រុក ទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង-ស្រុក តាមរយៈកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្ត បានទទួលការធ្វើសមាហរណកម្មការិយាល័យជំនាញនានាជុំវិញក្រុង ស្រុក ទៅក្នុងរចនាសម្ព័ន្ធថ្មី ដែលមានចំនួនសរុប **៨.២០៧** នាក់ ។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋបាលខេត្ត និងក្រុងស្រុកក៏ទទួលបានការធ្វើប្រតិភូកម្មអំណាចពីវិស័យមួយចំនួនក្នុងការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុកមាននៅគ្រប់ទាំង ១៤ក្រុង-ស្រុក។ ជាមួយគ្នានេះ ខេត្តបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋសរុបចំនួន **១៦៥.៩៣៥** ប័ណ្ណ។

ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋតាមរយៈយន្តការច្រកចេញចូលតែមួយក្នុងខេត្តសរុបចំនួន **៨៥៥.០១១**សេវា និងទទួលបានប្រាក់ចំណូលសរុប **១៦.១១៤.៣៧០.៤២១**រៀល ។

ក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះខេត្តបានអនុវត្តនូវគម្រោងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ដោយសម្រេចបានចំនួន **១.៧២៩** គម្រោង ថវិកាចំណាយលើគម្រោងវិនិយោគសរុបចំនួន **៣.៣៣៥.៣៧៩លាន**រៀល ដែលក្នុងនោះគម្រោងចំនួន **១.៥៥៥** គម្រោង ស្មើនឹង **៨៣%** ជាគម្រោងដែលបានអនុវត្តដោយចំណាយថវិកាជាតិ ។

**<u>២.ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ</u> ៖**

សភាពការណ៍សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ទាំងនៅក្នុងភូមិសាស្ត្រខេត្ត និងតាមតំបន់ព្រំដែន មានលក្ខណៈល្អប្រសើរ ដែលនេះជាលទ្ធផលស្តែងចេញពីមនសិការការងារ និងវិជ្ជាជីវៈ ការខិតខំប្រឹងប្រែងតស៊ូរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក និងគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងខេត្ត។ បទល្មើសជាទូទៅត្រូវបានបង្ក្រាបជាបន្តបន្ទាប់ សន្តិសុខសណ្តាប់ធ្នាប់ត្រូវបានធានា និងពង្រឹង ។ ជាក់ស្តែង បានបង្ក្រាបបទល្មើសព្រហ្មទណ្ឌនៅទូទាំងខេត្តចំនួន **៧២៧ ករណី** ស្មើនឹង **៩៤,៧៣%** , បទល្មើសគ្រឿងញៀនចំនួន **៣.៦៨៩** ករណី, បទល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទចំនួន **១៧១**ករណី, ល្បែងស៊ីសង **៩៨៣** ករណី និងក្មេងទំនើង **៣១០** ករណី។ ជាមួយគ្នានេះ ខេត្តបានរក្សាទំនាក់ទំនងយ៉ាងល្អជាមួយភាគីថៃ តាមរយៈការជួបប្រជុំពិភាក្សាដើម្បីផ្លាស់ប្តូរព័ត៌មាន

និងបង្កើនកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរ។ ទន្ទឹមនេះ កងកម្លាំងរក្សាសន្តិសុខព្រំដែន បានសហការជាមួយ សមត្ថកិច្ចថៃទទួលពលករត្រឡប់មកវិញចំនួន **១.៥៧៩** លើក ស្មើនឹងមនុស្ស **៣៦.៤០៣** នាក់។

ចំពោះលទ្ធផលនៃការប្រឡងប្រណាំងភូមិឃុំសង្កាត់មានសុវត្ថិភាពក្នុងឆ្នាំ២០២២នេះ ខេត្តបានទទួល ចំណាត់ថ្នាក់លេខ១ មានចំនួន ៨២ឃុំ សង្កាត់, លេខ២ មានចំនួន ១៥ ឃុំ សង្កាត់ និងលេខ៣ មានចំនួន ៦ ឃុំ សង្កាត់។

**៣.ការរៀបចំទីក្រុងស្អាត និងទីក្រុងឆ្លាត**

ក្រុងបាត់ដំបង ជាក្រុងមួយក្នុងចំណោមទីក្រុង ចំនួន ៣ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជ្រើសរើសជា បណ្តាញទីក្រុងឆ្លាតអាស៊ាន ដែលមានសមាជិកទីក្រុងចំនួន ២៦ ។ បណ្តាញទីក្រុងឆ្លាតអាស៊ាន ត្រូវបានផ្តួចផ្តើម ឡើងក្នុងឆ្នាំ២០១៨ មានក្របខ័ណ្ឌទីក្រុងឆ្លាតអាស៊ានដែលចង្អុលបង្ហាញអំពីយុទ្ធសាស្ត្រ ប្រព័ន្ធគ្រប់គ្រងទីក្រុង ប្រធានបទអភិវឌ្ឍដែលត្រូវផ្តោតយកចិត្តទុកដាក់ និងកត្តាជម្រុញការងារទីក្រុងឆ្លាត។ រដ្ឋបាលខេត្តបាត់ដំបង បាន លើកគម្រោងអភិវឌ្ឍធំចំនួន២ គឺ ការគ្រប់គ្រងលំហសាធារណៈនិងចំណីផ្លូវ និងការគ្រប់គ្រងសំណល់រឹង និងរាវ។ តាមរ យៈព្រឹត្តិការណ៍របស់បណ្តាញទីក្រុងឆ្លាតអាស៊ាន រដ្ឋបាលខេត្តបានធ្វើការទំនាក់ទំនងជាមួយដៃគូ អភិវឌ្ឍមួយចំនួន រួមមាន ក្រសួងដែនដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍ (MLIT) ប្រទេសជប៉ុន អង្គការ UNESCAP ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមហ៊ុនជប៉ុន។ ទន្ទឹមនេះ រដ្ឋបាលខេត្តក៏បានខិតខំតម្រង់ទិស ការអភិវឌ្ឍឱ្យ ស្របតាមគោលគំនិតទីក្រុងឆ្លាតផងដែរ។ ជាលទ្ធផលនៃការខិតខំ និងការចូលរួមពីអ្នកពាក់ព័ន្ធ រដ្ឋបាលខេត្ត ទទួល បាននូវសមិទ្ធផល ដូចខាងក្រោម៖

- លើកកម្ពស់សោភ័ណភាព សណ្តាប់ធ្នាប់ (រៀបចំសំយ៉ាប ស្លាកយីហោផ្សព្វផ្សាយពាណិជ្ជកម្ម ផ្លូ) តាមដងផ្លូវ សំខាន់ៗមួយចំនួននៅក្នុងក្រុង
- ផលិតបានផែនទីបង្ហាញផ្លូវ/ប្លង់គោលអភិវឌ្ឍន៍ក្រុងបាត់ដំបង ប្រកបដោយចីរភាព និងឆ្លាតវៃ
- ចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រុមហ៊ុនជប៉ុនចំនួន ៣ក្រុមហ៊ុន ដើម្បីសិក្សាជម្រុញ ការអនុវត្ត គម្រោងទីក្រុងឆ្លាត ក្រុងបាត់ដំបង ដែលបានលើកឡើងក្នុងផែនទីបង្ហាញផ្លូវ
- បានពិភាក្សាជាមួយធនាគារអភិវឌ្ឍអាស៊ី លើគម្រោងគ្រប់គ្រងហិរញ្ញវត្ថុឆ្លាតលើសេវាប្រមូលសំរាម ដូចជា ការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងបង្កើត ឱ្យមានការបង់សេវាប្រមូលសំរាមតាម អនឡាញ។

**៤-<u>វិស័យកសិកម្ម</u> ៖**

ដោយមានកត្តាអំណោយផលពីធម្មជាតិ អាកាសធាតុ សណ្ឋានដី និងដីដែលមានជីវជាតិខ្ពស់ និងប្រព័ន្ធ ស្រោចស្រពសម្បូរបែប ខេត្តបាត់ដំបងគឺជាខេត្តដែលមានភាពល្បីល្បាញលើវិស័យកសិកម្ម និងជាប់ឈ្មោះជាខេត្ត ជម្រុកស្រូវនៃព្រះរាជាណាចក្រកម្ពុជា។ ខេត្តមានប្រព័ន្ធធារាសាស្ត្រធំចំនួន ០៤ គឺ ទី១៖ ប្រព័ន្ធធារាសាស្ត្រស្ទឹងសង្កែ ដែលមានសក្តានុពលស្រោចស្រពនៅរដូវវស្សាចំនួន **៦២.១៣០**ហិកតា និងរដូវប្រាំងចំនួន **១៥.០០០** ហិកតា និង មានប្រជាពលរដ្ឋទទួលផលចំនួន **៤១.៣៨៥** គ្រួសារ, ទី២៖ប្រព័ន្ធធារាសាស្ត្រស្ទឹងមោងឫស្សីដែលមានសក្តានុពល ស្រោចស្រពនៅរដូវវស្សាចំនួន **៤០.២៥៨**ហិកតា និងរដូវប្រាំងចំនួន **២.០៥០**ហិកតា និងមានប្រជាពលរដ្ឋទទួល ផលចំនួន **២៤.២៥៤** គ្រួសារ, ទី៣៖ប្រព័ន្ធធារាសាស្ត្រស្ទឹងមង្គលបូរីដែលមានសក្តានុពលស្រោចស្រពនៅរដូវវស្សា ចំនួន **៥៥.៤៤០**ហិកតា និងរដូវប្រាំងចំនួន **៦.៥៤៤**ហិកតា និងមានប្រជាពលរដ្ឋទទួលផលចំនួន **៤៤.៣៥៥** គ្រួសារ និងទី៤៖ ប្រព័ន្ធធារាសាស្ត្រអាងកំពីងពួយដែលមានសក្តានុពលស្រោចស្រពនៅរដូវវស្សាចំនួន **២៤.០០០** ហិកតា និងរដូវប្រាំងចំនួន **១៨.៥០០**ហិកតា និងមានប្រជាពលរដ្ឋទទួលផលចំនួន **៦.០៨៧** គ្រួសារ ។ បច្ចុប្បន្ន ក្រោមជំនួយរបស់រដ្ឋាភិបាលកូរ៉េ ខេត្តកំពុងដំណើរការសាងសង់គម្រោងទំនប់ដូនទ្រី (ដែលគ្រោងនឹងបញ្ចប់នៅចុង ឆ្នាំ២០២៣) មានវិសាលភាពស្រោចស្រពនៅក្នុងស្រុកចំនួន៣របស់ខេត្ត (ស្រុកមោងឫស្សី រុក្ខគិរី និងស្រុកគាស់ក្រឡ)។

ខេត្ត ផ្ទៃដីដាំដុះស្រូវសរុបចំនួន **៤១៤.៧៦១** ហិកតា ដែលទទួលបានបរិមាណប្រមាណផលចន្លោះពី **១.១ លានតោន** ទៅ **១,៤លាន**តោន ក្នុងមួយឆ្នាំៗ។ រីឯផ្ទៃដីដំណាំសាកវប្បកម្ម និងឧស្សាហកម្មសរុបមានចំនួន **២៥៤.៩៧៤**ហិកតា ។ ក្នុងរយៈពេល៥ឆ្នាំនេះ ទិន្នផលស្រូវសរុបចំនួន **៦.៥០១.៨៨០**តោន, ពោតក្រហមចំនួន

២.៥៩៧.៥៧៧តោន, ដំឡូងមី ១៣.៩១២.០៣៣តោន, ស្វាយកែវល្មៀត ១.០៨៩.២៥៨តោន, មៀន ៣០.៤៧០ តោន និងស្វាយចន្ទី ២១.៧៥៦តោន។ ខេត្ត នាំចេញកសិផលទៅក្រៅប្រទេសតាមច្រកព្រំដែនខេត្តទៅប្រទេសថៃ និងវៀតណាម បានចំនួន **១.២០២.៤៤៨ តោន**។

ក្រៅពីដំណាំស្រូវ និងដំណាំឧស្សាហកម្ម ខេត្តបាត់ដំបងជាខេត្តដែលសម្បូរបែបទៅដោយដំណាំហូបផ្លែជាច្រើនប្រភេទ ជាពិសេស ដំណាំទុរេន ដែលត្រូវបានដាំដុះលើផ្ទៃដីប្រមាណ **៥៨៣** ហិកតា។ ខេត្តមានសហគមន៍កសិកម្មចំនួន **៨៣** កន្លែង ដែលមានទុនវិនិយោគសរុបចំនួន **៩.៤៤៦.៩៦៣.២៦៨**រៀល។

សហគមន៍នេសាទចំនួន **៤៧** សហគមន៍ ដែលមានសមាជិកសរុបចំនួន **១៦.២៣៨**នាក់។ ក្នុងរយៈពេល ៥ឆ្នាំនេះ ផលនេសាទសរុបទទួលបានចំនួន **២៤៥.៥៣១តោន** ដែលក្នុងនោះ បានកែច្នៃផលនេសាទសម្រាប់ធ្វើការនាំចេញសរុបចំនួន **៣០.៣៤៨**តោន។

**៥-<u>វិស័យពាណិជ្ជកម្ម និងការវិនិយោគ</u> ៖**

ក្រុមហ៊ុនវិនិយោគ និងរោងចក្រធំៗនៅក្នុងខេត្ត មានដូចជា រោងម៉ាស៊ីនកិនស្រូវ រោងចក្រកែច្នៃដំឡូងមី និងពោត រោងចក្រស៊ីម៉ង់ត៍ រោងចក្រផលិតថ្នាំពេទ្យ រោងចក្រកែច្នៃក្រដាស រោងចក្រស្បែកជើង និងរោងចក្រ សហគ្រាស គ្រឹះស្ថាន ផ្សេងៗទៀតសរុបចំនួន **៧៣៦ មូលដ្ឋាន** ដែលបានផ្តល់ការងារដល់កម្មករចំនួនជាង **១៤.៩៧៣**នាក់។

ខេត្តមានព្រំប្រទល់ជាប់នឹងខេត្តមួយចំនួនរបស់ព្រះរាជាណាចក្រថៃ ដែលនេះគឺកត្តាជាអំណោយផលមួយដល់ការដោះដូរ-ដឹកជញ្ជូនទំនិញ ការធ្វើពាណិជ្ជកម្ម ការធ្វើដំណើរ ចេញចូល ទេសចរណ៍ ការធ្វើកិច្ចសហប្រតិបត្តិការ និងបានជួយជម្រុញដល់កំណើនសេដ្ឋកិច្ចរបស់ខេត្តផងដែរ។ ទំនិញនាំចេញរបស់ខេត្តបាត់ដំបង ទៅប្រទេសថៃភាគច្រើនជាប្រភេទកសិផល ដូចជា ពោតក្រហម ដំឡូងមី ស្វាយកែវល្មៀត និងនាំចូលមកវិញភាគច្រើនជាគ្រឿងសំណង់ និងសម្ភារៈប្រើប្រាស់ គ្រឿងសង្ហារឹម ភេសជ្ជៈ និងគ្រឿងឧបភោគបរិភោគ ។

**៦-<u>វិស័យទេសចរណ៍</u> ៖**

ខេត្តបាត់ដំបងជាខេត្តមួយដែលមានភោគផលធម្មជាតិសម្បូរបែប និងទីតាំងប្រវត្តិសាស្ត្រ វប្បធម៌ រមណីយដ្ឋានជាច្រើន ដែលជាប្រភពសក្តានុពល ក្នុងការទាក់ទាញភ្ញៀវទេសចរទាំងជាតិ និងអន្តរជាតិមកទស្សនា សម្រាកលំហែកាយ និងកំសាន្ត នៅតាមបណ្តាតំបន់ទេសចរណ៍នានាក្នុងខេត្ត ទាំងតំបន់ទេសចរណ៍ធម្មជាតិ កែច្នៃ វប្បធម៌ និងប្រវត្តិសាស្ត្រ ដែលបានទាក់ទាញនិងមានកំណើនភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិមកទស្សនាជារៀងរាល់ឆ្នាំ។ ខេត្តបាត់ដំបងក៏ជាខេត្តមួយដែលត្រូវបានប្រសិទ្ធនាមជាខេត្តនៃអាហារ ដែលប្រជាជនខេត្តបាត់ដំបង មានភាពច្នៃ ប្រឌិតខ្ពស់ និងបានរួមចំណែកមួយក្នុងការទាក់ទាញភ្ញៀវទេសចរណ៍ក្នុងស្រុក។

ជាមួយគ្នានេះ ខេត្តមានសណ្ឋាគារចំនួន **៤៦** កន្លែង ផ្ទះភ្ញៀវ និងផ្ទះស្នាក់ **៩៧** កន្លែង និងភោជនីយដ្ឋាន-អាហារដ្ឋានចំនួន **១៩១**កន្លែង ដែលបានកំពុងដំណើរការផ្តល់ជូននូវសេវាស្នាក់នៅ និងចំណីអាហារ ប្រកបដោយភាពកក់ក្តៅ និងមានគុណភាពជូនដល់ភ្ញៀវជាតិ និងអន្តរជាតិ។ ខេត្តមានសហគមន៍ទេសចរណ៍ចំនួន ០៤ កន្លែង គឺសហគមន៍អេកូទេសចរណ៍ព្រែកទាល់ (ស្រុកឯកភ្នំ) សហគមន៍អេកូទេសចរណ៍ទឹកធ្លាក់អូរដាំ និងសហគមន៍អេកូទេសចរណ៍តាតោកអូរក្រូច (ស្រុកសំឡូត) និងសហគមន៍ទេសចរណ៍វប្បធម៌ភូមិវត្តគរ ក្រុងបាត់ដំបង ដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋានតាមរយៈការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងជួយដល់ប្រជាកសិករ និងប្រជាជនទៅតំបន់នោះឱ្យមានការងារធ្វើ និងទទួលបានប្រាក់ចំណូលបន្ថែម។ បន្ថែមលើសពីនេះ ខេត្តនៅមានទីតាំងទេសចរណ៍ធម្មជាតិជាច្រើនកន្លែងទៀតដែលកំពុងរៀបចំ កែលំអ ជាបន្តបន្ទាប់។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ (២០១៨-២០២២) ភ្ញៀវទេសចរជាតិ និងអន្តរជាតិមកទស្សនាខេត្តបាត់ដំបងសរុបចំនួន **២.៥៧១.៦៨៧** នាក់ ក្នុងនោះ ភ្ញៀវទេសចរជាតិចំនួន **២.៣១៤.១២៦** នាក់ និងភ្ញៀវទេសចរអន្តរជាតិចំនួន **២៥៧.៥៦១** នាក់។

ទន្ទឹមនេះ ខេត្តបានរៀបចំព្រឹត្តិការណ៍ធំៗជាច្រើនជារៀងរាល់ឆ្នាំ ដែលការណ៍នេះក្លាយជាកត្តាទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិមកទស្សនាយ៉ាងច្រើនកុះករ ដូចជា ការសហការរៀបចំពិធីបុណ្យទន្លេលើកទី៦ កាលពីឆ្នាំ២០២០, ពិធីសង្ក្រាន្តបាត់ដំបងដើម្បីអបអរសាទរបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ, ពិធីបុណ្យអុំទូកបណ្តែតប្រទីបខេត្ត កម្មវិធីឆ្លងឆ្នាំសកល និងពិធីតាំងពិព័រណ៌ផ្សេងៗជាច្រើនទៀត។ ជាមួយគ្នានេះផងដែរ ខេត្តក៏បានទទួលពានរង្វាន់ជ័យលាភីខេត្ត

ជាច្រើនសំខាន់ៗ រួមមាន ពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី១ (២០១៨-២០២០) នៅក្នុងវេទិកាទេសចរណ៍អាស៊ាន នៅខេត្តឈៀងម៉ៃ ប្រទេសថៃ, ពានរង្វាន់ទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី៣ (២០២២-២០២៤) ក្នុងវេទិកាទេសចរណ៍អាស៊ាន នៅក្រុងព្រះសីហនុ ប្រទេសកម្ពុជា និងពានរង្វាន់ផ្ការំដួលពាទង លើកទី១ និងលើកទី២ ជាដើម។ ថ្មីៗនេះ ខេត្តបាត់ដំបងបានទទួលជ័យលាភីលេខ១ ជាទីក្រុងដែលមានពិធីបុណ្យចូលឆ្នាំសាកលល្អជាងគេប្រចាំឆ្នាំ២០២២។

**៧-<u>វិស័យសាធារណការ និងផ្លូវលំជនបទ</u> ៖**

ខេត្តបាត់ដំបង បានបន្តការស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដោយផ្តោតសំខាន់លើការងារកសាង ជួសជុលថែទាំ ផ្លូវជាតិ ផ្លូវខេត្ត និងបន្តកសាងផ្លូវខេត្ត ផ្លូវជនបទ ឱ្យមានគុណភាពខ្ពស់ ក្នុងគោលបំណងតភ្ជាប់បណ្តាញផ្លូវពីទីរួមខេត្ត ទៅស្រុក និងពីស្រុកមកទីរួមខេត្ត ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ចរបស់ខេត្ត។ បច្ចុប្បន្ននេះខេត្ត មានផ្លូវកៅស៊ូឆ្លងកាត់ ឃុំ-សង្កាត់ សរុបចំនួន ៩៧ឃុំ-សង្កាត់ លើ ១០៣ ឃុំ-សង្កាត់ ។ មានផ្លូវជាតិឆ្លងកាត់ចំនួន ៧ខ្សែ (សរុបប្រវែង ៥០៩,៥៥ គ.ម), ផ្លូវខេត្ត សរុបចំនួន ៤០ ខ្សែ (ផ្លូវក្រាលកៅស៊ូ ប្រវែង ២៤៧,៨៥គ.ម និងផ្លូវក្រាលដីល្បាយថ្ម ប្រវែង ៤៥៥,៥គ.ម) និងមានផ្លូវរថភ្លើងចំនួន ១ខ្សែ ដែលជា បណ្តាញ ដឹកជញ្ជូនទំនិញដ៏សំខាន់របស់ខេត្ត ទាំងក្នុងប្រទេស និងក្រៅប្រទេសជាមួយប្រទេសថៃ ។ ខេត្តមានសំណង់ស្ពាន ជាច្រើនកន្លែងឆ្លងកាត់ស្ទឹងសង្កែ (ដែលពីមុនមានតែចំនួន៣ ដល់បច្ចុប្បន្នមានរហូតដល់ ១៨កន្លែង) ។ ជាពិសេសថ្មីៗនេះ ការកសាងកំណាត់ផ្លូវប្រវែង **៨៤,៧៤** គម នៃគម្រោងធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ៥ បាត់ដំបង-សេរីសោភ័ណ ត្រូវបានបញ្ចប់ជាស្ថាពរ និងបានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)។** មួយវិញទៀត ខេត្តបានបញ្ចប់ការសាងសង់ទីលានកប់សំរាមមួយកន្លែង ដែលប្រើប្រាស់ផ្ទៃដីសរុប **២០,៨**ហិចតា (មានអគារស្នាក់នៅ, ការិយាល័យ, ជញ្ជីងថ្លឹង, រោងញែកសំរាម, រោងជាង, រោងសំណល់គ្រោះថ្នាក់, កន្លែងលាងរថយន្ត, រណ្តៅសំណល់ គ្រោះថ្នាក់, រណ្តៅកប់សំរាមទី១, អាងប្រព្រឹត្តកម្មទឹកកខ្វក់ចេញពីសំរាម និងបំរុងសម្រាប់រណ្តៅកប់សំរាម)។

**គួរបញ្ជាក់ផងដែរថា** គម្រោងសាងសង់ផ្លូវជាតិលេខ១០ ដែលចេញពីស្រុកសំឡូត ខេត្តបាត់ដំបង ឆ្លងកាត់ខេត្តពោធិ៍សាត់ ឆ្ពោះទៅកាន់ខេត្តកោះកុង ក្រោមជំនួយរបស់រដ្ឋាភិបាលប្រទេសចិន បាននឹងកំពុងដំណើរការសាងសង់សម្រេចបានប្រមាណ **៦៩,២៨%** ដែលនឹងគ្រោងបញ្ចប់នៅចុងឆ្នាំ២០២៤។

ចំពោះផ្លូវលំជនបទ ក្នុងរយៈពេល៥ឆ្នាំនេះ ខេត្តបានកសាងផ្លូវទាំងក្រាលកៅស៊ូ ក្រួសក្រហម និងដីសចំនួន **២៣៤**ខ្សែ ប្រវែង **១.៣១៥,៦**គីឡូម៉ែត្រ ព្រមទាំងបានសាងសង់បង្គន់សាធារណៈចំនួន **៤៤** បង្គន់, បង្គន់អនាម័យគ្រួសារ **២.២៣៨**បង្គន់, សាងសង់អណ្តូងស្នប់ **៤០៨**អណ្តូង និងផ្តល់ពាងត្រងទឹកភ្លៀងចំនួន **២៧.៥៣៤**ពាង។

**៨-<u>វិស័យអប់រំ</u> ៖**

គិតមកដល់ឆ្នាំ២០២២នេះ ខេត្តមានសាលារៀនសាធារណៈគ្រប់ភូមិសិក្សាសរុប **១.១៧០** សាលា សាលារៀនឯកជនចំនួន **៦១** សាលា មត្តេយ្យសហគមន **២៣១** សាលា និងសាលាសាសនា **២** សាលា។ ក្រៅពីសាលាអប់រំចំណេះទូទៅ ខេត្តមានសាកលវិទ្យាល័យរដ្ឋចំនួន **២** កន្លែង គឺសាកលវិទ្យាល័យបាត់ដំបង **១** កន្លែង ដែលកសាងឡើងដោយ**សម្តេចក្រឡាហោម ស ខេង** និងសាកលវិទ្យាល័យព្រះសីហនុរាជ និងមានសាកលវិទ្យាល័យសាខាសាកលវិទ្យាល័យ វិទ្យាស្ថាន សាខាវិទ្យាស្ថាន ដែលជាកម្មសិទ្ធិរបស់ឯកជនចំនួន **៩** កន្លែងផ្សេងទៀត ។

ជាមួយនឹងសមិទ្ធផលខាងលើ រដ្ឋបាលខេត្តបាត់ដំបងបានទទួលនូវអគារសិក្សាចំនួន **២៦២** ខ្នង ស្មើនឹង **១.៧៦១** បន្ទប់ (ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ខេត្តបានទទួលអគារចំនួន **៣៣** ខ្នង ស្មើនឹង **២៥០** បន្ទប់) ដែលជាអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងសម្តេចគតិព្រឹទ្ធបណ្ឌិត ចំនួន **៧** ខ្នង **៩០** បន្ទប់ **សម្តេចក្រឡាហោម ស ខេង** ចំនួន **៧** ខ្នង **៩៩** បន្ទប់ និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានចំនួន **១៩** ខ្នង **៦១** បន្ទប់។ នៅឆ្នាំ២០១៧ បន្ទាប់ក្រសួងអប់រំ យុវជន និងកីឡាបានបញ្ចូលសាលាគរុកោសល្យ និងវិក្រឹត្យការខេត្ត ជាមួយសាលាគរុកោសល្យភូមិភាគខេត្តបាត់ដំបង ប្រែក្លាយទៅជាវិទ្យាស្ថានគរុកោសល្យបាត់ដំបង ។ វិទ្យាស្ថាននេះ មានអគារសិក្សា អគាររដ្ឋបាល និងអគារអន្តេវាសិកដ្ឋាន សរុបចំនួន

៥ខ្នង ដែលជាជំនួយរបស់អង្គការ JICA ព្រមទាំងបណ្តុះបណ្តាលគ្រូលើកម្រិតបឋមសិក្សា និងកម្រិតមធ្យមសិក្សាបឋមភូមិ ដោយអាចគ្របដណ្តប់លើ១៤ខេត្ត នៅទូទាំងប្រទេស។

ក្នុងឆ្នាំសិក្សា ២០២១-២០២២ សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិសរុបមានចំនួន **៦៨,៣%** ដែលក្នុងនោះ សិស្សទទួលបាននិទ្ទេសA ចំនួន **៥៤** រូប ។

**៩-ការងារសុខាភិបាល ៖**

ខេត្តបាត់ដំបងមានមូលដ្ឋានផ្តល់សេវាសាធារណៈចំនួន **៨៩** កន្លែង ក្នុងនោះ មន្ទីរពេទ្យបង្អែកខេត្តចំនួន **០១** កន្លែង និងមន្ទីរពេទ្យបង្អែកស្រុក **០៦** កន្លែង មណ្ឌលសុខភាពចំនួន **៨២** កន្លែង និងប៉ុស្តិ៍សុខភាពចំនួន **០២**កន្លែង។ ក្រៅពីនេះ ខេត្តមានមូលដ្ឋានផ្តល់សេវាឯកជនចំនួន **៤៣** កន្លែង និងបន្ទប់ពិគ្រោះថៃទាំជំងឺចំនួន **៧១៨** កន្លែង។ ខេត្តបានទទួលនូវអគារសម្ភព និងថៃទាំទារក ជំនួយរបស់អង្គការ KOFIH ប្រទេសកូរ៉េខាងត្បូង និងអគារវះកាត់ និងសម្រាកពេទ្យ ជាជំនួយរបស់អង្គការ JICA ប្រទេសជប៉ុន។

ព្រឹត្តិការណ៍ ២០ កុម្ភៈ ឆ្នាំ២០២០ បានធ្វើឱ្យមានការផ្ទុះឡើងការរីករាលដាលជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។ ដោយអនុវត្តតាមយុទ្ធសាស្ត្រ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ យុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រទាំង៦ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** គឺយុទ្ធនាការនៃការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋទូទាំងប្រទេស។ ដែលក្នុងនោះខេត្តបាត់ដំបង បានបន្តអនុវត្តយុទ្ធសាស្ត្រនេះយ៉ាងម៉ឺងម៉ាត់ ជាលទ្ធផលស្ថិតិប្រជាពលរដ្ឋដែលបានចាក់វ៉ាក់សាំងរួមមាន លើកទី១បាន **៩៥១.៣៧៨** នាក់, លើកទី២បាន **៨៨៨.៨៩៩** នាក់, លើកទី៣បាន **៥៧២.៣៥៥** នាក់, លើកទី៤បាន **២៤៣.៨៧៥** នាក់ និងលើកទី៥ បាន **៤៧.៦៩៥** នាក់។

**១០-ស្ថានភាពនៃការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីក្នុងខេត្ត ៖**

រដ្ឋបាលខេត្តបានដាក់ចេញនូវផែនការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី ដើម្បីធានាបាននូវប្រសិទ្ធភាព និងកាត់បន្ថយនូវបញ្ហាប្រឈមនានាទាក់ទងនឹងដីធ្លី ដូចជា ៖

-បានរៀបចំផែនការរៀបចំដែនដីខេត្តបាត់ដំបង ដែលអនុម័តដោយរាជរដ្ឋាភិបាល និងប្លង់គោលប្រើប្រាស់ដីក្រុងបាត់ដំបងដែលអនុម័តដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ។

-បានកសាងផែនការប្រើប្រាស់ដី នៅឃុំចំនួន ៣០ឃុំ នៅស្រុកចំនួន ០៤ មានស្រុកបវេល ថ្មគោល មោងឫស្សី និងស្រុករុក្ខគិរី ដែលអនុម័តដោយគណៈកម្មាធិការរៀបចំដែនដី និង នគរូបនីយកម្មខេត្ត។

-ការងារអភិវឌ្ឍ រដ្ឋបាលខេត្តបានទទួលពាក្យស្នើសុំចំនួន **១៦៥** គម្រោង និងបានចេញលិខិតអនុញ្ញាតចំនួន **១៥៤**គម្រោង ស្មើនឹង **១០.៦៧០**ឡូតិ៍ និងមានទុនវិនិយោគចំនួន **២២.០០២.៧៤៨**ដុល្លាអាមេរិក។

-ការងារសំណង់៖ បានពង្រឹងការអនុវត្តវិធានការសំណង់ និងត្រួតពិនិត្យការអនុញ្ញាតសាងសង់ដោយបានចេញ លិខិតអនុញ្ញាតសាងសង់មានចំនួន **២២២** គម្រោង មានផ្ទៃក្រឡាសរុប **៤៧០.០០៣,១៩**ម$^{២}$ និងរបងបេតុងប្រវែង**៥.៩៤០,៦**ម ដែលមាន ទុនវិនិយោគ ប្រមាណ **១២០.៣២៩.២៨២,១** ដុល្លារ។

គិតមកដល់បច្ចុប្បន្ន ខេត្តបានអនុវត្តបញ្ចូលទិន្នន័យក្បាលដីចំនួន **៤៣០.៧៩៨** ក្បាលដី និងចែក បណ្ណកម្មសិទ្ធជូនដល់ប្រជាពលរដ្ឋរួចរាល់ចំនួន ៤១៤.**៩២៦**ប័ណ្ណ លើ**៥៤០**ភូមិ **៧៦**ឃុំ-សង្កាត់ និង **១៤**ក្រុង-ស្រុក ។

-ការដោះស្រាយវិវាទដីធ្លី ៖ ការសម្របសម្រួល ដោះស្រាយវិវាទដីធ្លី រដ្ឋបាលខេត្តបានប្រើប្រាស់យន្តការចំនួនពីរ៖ (ទី១)គណៈកម្មការចម្រុះខេត្តដោះស្រាយវិវាទដីធ្លី និង(ទី២) គណៈកម្មការសុរិយោដី។ រដ្ឋបាលខេត្តកំពុងពិនិត្យ ចាត់ចែងសម្របសម្រួលករណីវិវាទដីធ្លីចំនួន ៥៣៦ករណី ក្នុងនោះបានដោះស្រាយបញ្ចប់ចំនួន ២៤២ ករណី បានច្រានចោលចំនួន ១៣១ ករណី សាមីបណ្តឹងបានស្នើសុំដកពាក្យវិញចំនួន ៤៣ ករណី កំពុងបន្តដោះស្រាយចំនួន៧០ ករណី និងបានបញ្ជូនទៅថ្នាក់ជាតិចំនួន ៥០ ករណី។ ទន្ទឹមនេះផងដែរ ក៏បានចូលរួមជាមួយក្រុមការងារនៃគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់លើដីធ្លី ផ្ទះសម្បែង និងផលដំណាំផ្សេងៗលើគម្រោងអភិវឌ្ឍនានារបស់រាជរដ្ឋាភិបាល ។ បន្ថែមជាងនេះទៀត ខេត្តបាត់ដំបងបានធ្វើការបោសសំអាតមីន និងយុទ្ធភ័ណ្ឌ

មិនទាន់ផ្ទុះក្នុងរយៈពេល៥ឆ្នាំនេះ សម្រេចបានលើផ្ទៃដីទំហំ **១៨.៩៥៧** ហិកតា និងបានយកមកប្រើប្រាស់ជាដីកសិកម្ម និងដីលំនៅដ្ឋាន ចំនួនទំហំ **១៥.៦០២** ហិកតា និងជាដីហេដ្ឋារចនាសម្ព័ន្ធរូបវន្តទំហំ **៣.៣៥៥** ហ.ត។

**១១-វិស័យអគ្គិសនី និងទឹកស្អាត ៖**

ខេត្តបាត់ដំបង បានទទួលការផ្គត់ផ្គង់ថាមពលពីប្រព័ន្ធខ្សែបញ្ជូនជាតិ115គីឡូវ៉ុល ពីប្រទេសថៃ និង 230 គីឡូវ៉ុលពីភ្នំពេញ និងមានម៉ាស៊ីនភ្លើងបម្រុងសរុបចំនួន ០៤ គ្រឿង ព្រមទាំងមានសេវាករចែកចាយអគ្គិសនីសរុបចំនួន ៣៣អាជ្ញាប័ណ្ណ។ តម្រូវការប្រើប្រាស់ក្នុងខេត្តបាត់ដំបងសរុប 79,54 មេកាវ៉ាត់។ គ្រួសារប្រជាពលរដ្ឋខេត្តបាត់ដំបងចំនួន **៩០,៣២%** មានអគ្គិសនីប្រើប្រាស់។ សូមគូសបញ្ជាក់ផងដែរថា ខេត្ត កំពុងធ្វើការពង្រីកការតភ្ជាប់បណ្តាញអគ្គិសនីបន្ថែមទៀតដល់មូលដ្ឋានភូមិ ឃុំ ជាពិសេសនៅតាមតំបន់ជនបទ ។

ចំពោះតំបន់សេវាទឹកស្អាតរបស់អង្គភាពរដ្ឋាករទឹកបាត់ដំបងអនុវត្តការងារផ្គត់ផ្គង់ទឹកស្អាតបាន **០៣** ក្រុង-ស្រុក ស្មើនឹង**១៦**ឃុំ-សង្កាត់ ស្មើនឹង **៨៥**ភូមិ ដែលជាដែនសេវាកម្មអាជ្ញាប័ណ្ណរបស់អង្គភាពដែលមាន ប្រជាជនទទួលបានសេវាទឹកស្អាត បាន **៦៨,៧៥**% ។ ក្រៅពីអង្គភាពរដ្ឋាករទឹកបាត់ដំបង ខេត្តមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន **២៤** កន្លែងទៀត នៅតាមបណ្តាស្រុក ដែលកំពុងផ្តល់សេវាទឹកស្អាតជូនដល់ប្រជាពលរដ្ឋចំនួន **៤៥១** ភូមិ ។

**១២.វិស័យព័ត៌មាន**

ការងារព័ត៌មាន បានធ្វើការផ្សព្វផ្សាយតាមប្រពន្ធ័វិទ្យុនិងទូរទស្សន៍ជាតិខេត្ត ដោយផ្តោតការយកចិត្តទុកដាក់ លើកកម្ពស់អភិបាលកិច្ចល្អនិងកិច្ចអភិវឌ្ឍន៍សង្គមជាតិ ដោយគោរព និងអនុវត្តតាមគោលការណ៍វិជ្ជាជីវៈ បានផលិតកម្មវិធីនិង ផ្តល់ព័ត៌មានត្រឹមត្រូវទាន់ពេលវេលា ធ្វើជាស្ពានចំលងនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលជូនដល់ប្រជាពលរដ្ឋ និងពីប្រជាពលរដ្ឋទៅរាជរដ្ឋាភិបាល និងផ្តល់ឱកាសដល់អ្នកស្តាប់ បានចូលរួមសម្តែងនូវមតិចំណាប់អារម្មណ៍ពីតម្រូវការចាំបាច់ ពីបញ្ហាប្រឈមផ្សេង ៗ ដែលទាក់ទងទៅនិងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍សង្គមជាតិ ដោយបានជួបជជែក ពិភាក្សាជាមួយវាគ្មិន ជាមន្ត្រីរាជរដ្ឋាភិបាល អាជ្ញាធរគ្រប់ថ្នាក់ អង្គការដៃគូសង្គមស៊ីវិល ផ្នែកឯកជននិងប្រជាពលរដ្ឋ ចែករំលែកនូវបទពិសោធន៍ បង្កើតនូវចំណេះដឹងក្នុងការរកដំណោះស្រាយរួមគ្នា គោរព និងអនុវត្តន៍តាមគោលការណ៍នៃច្បាប់ ប្រកបដោយតម្លាភាព គណនេយ្យភាពនិងការទទួលខុសត្រូវ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្នុងឆ្នាំ២០១៨ ដោយបានការយកចិត្តទុកដាក់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មានបាននាំបំពាក់ម៉ាស៊ីនផ្សាយទូរទស្សន៍ថ្មីមួយគ្រឿងមានកំលាំងធំជាងមុន៥ដង ៥០០០វ៉ាត់ ដែលអាចធ្វើឱ្យប្រជាពលរដ្ឋនៅតំបន់ឆ្ងាយៗទស្សនាបានពីកម្មវិធីផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជាខេត្ត ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យមហាប្រសើរថ្លៃថ្លាជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាន នៅក្នុងសន្និសីទសារព័ត៌មាននេះ សូមបានប្រកបនូវពុទ្ធពរ ទាំងបួនប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។